# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC) Project

ខែ ធ្នូ ២០១០ ឆ្នាំទី ១ លេខ ៤

## ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស

### គម្រោង IBEC

- មានរយៈពេល៥ឆ្នាំ ចាប់ពីខែតុលា ២០០៩ ដល់ខែកញ្ញា ២០១៤
- សកម្មភាពប្រតិបត្តិមាននៅក្នុងខេត្ត ៣ គឺ ខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តសៀមរាប
- មានថវិកាចំនួន ១០ លានដុល្លាសហរដ្ឋអាមេរិក
- ជួយដល់សាលាបឋមសិក្សាចំនួន ២០២ សាលា និងសាលាមធ្យមសិក្សាបឋមភូមិចំនួន ១០១ សាលា

### ដៃគូរបស់គម្រោង IBEC

គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានទទួលថវិកាពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។ គម្រោងនេះត្រូវបានប្រតិបត្តិដោយអង្គការអប់រំពិភពលោក (World Education) ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) និងសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា (MoEYS) ។

*ដៃគូក្នុងស្រុកមានអង្គការ :*
WC RD, BSDA, NEP និង EDA

*ដៃគូអន្តរជាតិមានអង្គការ :*
Equal Access និងវិទ្យាស្ថានស្រាវជ្រាវសហរដ្ឋអាមេរិក (AIR)

## ជោគជ័យដែលសម្រេចបានរបស់គម្រោង IBEC នាដំណាច់ឆ្នាំទីមួយ







នៅថ្ងៃទី ៣០ ខែកញ្ញា ២០១០ គម្រោង IBEC បានបញ្ជាក់ឱ្យឃើញថាការអនុវត្តន៍គម្រោងឆ្នាំទីមួយត្រូវបានបញ្ចប់ដោយជោគជ័យ ។ IBEC គឺជាគម្រោងដ៏ធំមួយនាពេលបច្ចុប្បន្នដែលកំពុងប្រតិបត្តិលើវិស័យអប់រំក្នុងប្រព័ន្ធនៅកម្ពុជា ហើយគាំទ្រថវិកាដោយ USAID ។

កិច្ចប្រតិបត្តិការគម្រោងកំពុងអនុវត្តនៅក្នុងសាលាជាសរុបចំនួន ៣០៣ ដែលមាននៅក្នុងខេត្តកំពង់ចាម ក្រចេះ និងខេត្តសៀមរាប ។ IBEC មានលក្ខណៈពិសេសលើយុទ្ធសាស្ត្រអភិវឌ្ឍន៍គឺរៀបចំធ្វើឡើងដោយអ្នកដែលពាក់ព័ន្ធផ្ទាល់ ដូចជាសកម្មភាពបញ្ជី សកម្មភាពអំណោយសាលារៀន សកម្មភាពផែនការអនុវត្តកម្មវិធីគ្រប់វិស័យដែលផ្អែកទៅលើបរិបទទាំង៦នៃសាលាកុមារមេត្រីរបស់ក្រសួងអប់រំ និងការប្រើប្រាស់គណៈកម្មាធិការតាមមូលដ្ឋានដើម្បីដឹកនាំរាល់ការអនុវត្តន៍សកម្មភាពផ្សេងៗដោយផ្ទាល់ ។

IBEC បានពង្រីកបន្ថែមនូវកម្មវិធីមុនៗដែលឧបត្ថម្ភគាំទ្រដោយUSAID និងដាក់បញ្ចូលផ្ដោតសំខាន់ទៅលើការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាដោយបង្កើតនូវបរិបទដែលគាំទ្រដល់ការអប់រំបំណិនជីវិត ការវិនិយោគលើការរៀបចំប្រព័ន្ធទឹក និងប្រព័ន្ធទឹកស្អាតនៅតាមសាលាបឋម និងមធ្យមសិក្សា និងផ្ដោតសំខាន់ទៅលើការអភិវឌ្ឍន៍នូវរចនាសម្ព័ន្ធនៃស្ថាប័នមូលដ្ឋាន (ជាពិសេសអង្គការដែលជាដៃគូក្នុងស្រុក និងការគ្រប់គ្រងដឹកនាំក្នុងមូលដ្ឋាន) ។

ទោះបីជាការចាប់ផ្ដើមដំណើរការគម្រោងស្របពេលដែលសាលាបើកបវេសនកាលនៅខែតុលា ២០០៩ យ៉ាងណាក៏ដោយ ក៏ដៃគូអភិវឌ្ឍន៍គម្រោង IBEC បានបំពេញនូវការអនុវត្តន៍សកម្មភាពតែក្នុង៦ទៅ៧សប្តាហ៍ប៉ុណ្ណោះ ដោយធ្វើឱ្យគម្រោងរៀបចំការជួយដល់សាលាទទួលបានលទ្ធផលជាទីកត់សំគាល់នាកំឡុងឆ្នាំទីមួយនេះ ។ នៅចុងខែតុលា២០០៩ដៃគូក្នុងស្រុកបានបែងចែកនូវជំនួយបច្ចេកទេស និងសម្ភារៈដល់សាលានានា ។ នៅដើមខែវិច្ឆិកា ២០០៩សាលាបឋមសិក្សាចំនួន ១៣៣ និងសាលាមធ្យមសិក្សាចំនួន ៥៦ បានចាប់ផ្ដើមទទួលអំណោយឧបត្ថម្ភគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា ។ ជាសរុប IBEC បានបែងចែកទឹកប្រាក់ដែលត្រូវចំណាយជាសរុបចំនួន ១៣០ ៩៧៥ ដុល្លាសហរដ្ឋអាមេរិក ឱ្យដល់សាលានានានៅក្នុងឆ្នាំទីមួយនេះ ដែលជាផ្នែកមួយនៃការសម្រេចអនុវត្តលើគម្រោងនៅតាមមូលដ្ឋាន ។ នៅដំណាច់ឆ្នាំទីមួយនេះ ចំនួនសាលាដែលបានចូលរួម បានកើនដល់ចំនួន ២០២ ចំពោះសាលាបឋមសកិក្សា និងសាលាមធ្យមសិក្សាចំនួន ១០១ ជាសរុបមានចំនួន ៣០៣ សាលា ។

អំណោយផ្ទាល់ដល់សាលារៀននៃគម្រោង IBEC ត្រូវបានអនុវត្តសម្រេចទាំងស្រុងនៅឆ្នាំទី១ ដោយប្រព័ន្ធទឹក និងការកែលម្អអនាម័យទឹកស្អាតទទួលបានចំនួន (១៣២ ០០០ ដុល្លា) គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធចំនួន (៦១ ០០០ ដុល្លា) បន្ទប់វិទ្យាសាស្ត្រកុំព្យូទ័រចំនួន(៨៤ ០០០ដុល្លា) សម្ភារៈថ្នាក់រៀនចំនួន (៣៥ ០០០ដុល្លា) អាហារូបករណ៍ចំនួន(៨៣ ០០០ដុល្លា) និងគ្រូសហគមន៍ចំនួន(៤៩ ០០០ដុល្លា) និងផ្នែកផ្សេងៗទៀត រួមមានកម្មវិធីវិទ្យុដែលនិយាយពីកម្មវិធីបំណិនជីវិតដោយផ្សារភ្ជាប់ទៅនឹងការស្ដាប់និងក្រុមសន្ទនាឆ្លើយឆ្លងតាមសាលារៀន ។

នៅដំណាច់ឆ្នាំទីមួយនេះ កិច្ចប្រតិបត្តិនៃគម្រោង IBEC បានអនុវត្តនៅតាមគ្រប់ខេត្តគោលដៅទាំងអស់ ដោយរៀបចំការដឹកនាំយ៉ាងហ្មត់ចត់ ផ្សារភ្ជាប់ការអនុវត្តន៍រួមគ្នានៅគ្រប់លំដាប់ថ្នាក់ហើយក៏បានរៀបចំផងដែរសំរាប់ការពង្រីកបន្ថែមនៅឆ្នាំទី២ ចំពោះសកម្មភាពអនុវត្តសាកល្បងដ៏សំខាន់លើផ្នែកអប់រំបំណិនជីវិតនៅតាមសាលាកម្រិតមធ្យមសិក្សា ។

ព្រឹត្តិបត្រព័ត៌មានរបស់ IBEC លេខនេះបង្ហាញឱ្យឃើញនូវសមិទ្ធិផលដែលធ្វើបានដោយជោគជ័យនៅឆ្នាំទីមួយរបស់សមាសភាគទាំង៤នៃគម្រោង ។

*ព្រឹត្តិបត្រព័ត៌មាននេះអាចផលិតទៅបានដោយមានការឧបត្ថម្ភ ក្រោមជំនួយសប្បុរសធម៌ពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។*
*រាល់ខ្លឹមសារនៅក្នុងព្រឹត្តិបត្រនេះ ជាការទទួលខុសត្រូវរបស់អង្គការអប់រំពិភពលោក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID រឺរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។*
*ការិយាល័យអង្គការអប់រំពិភពលោក : ផ្ទះលេខ ២០ ផ្លូវ ២២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ ៨៥៥-២៣-២១ ៦៨ ៥៤ ទូរសារលេខ ២១៨ ៣៦៩ E-mail: worldedcam@worlded.org.kh*

## សមិទ្ធិផលធំៗដែលគម្រោង IBEC សម្រេចបាននៅឆ្នាំទី១



គម្រោងIBECបានបង្កើត និងចាក់ផ្សាយតាមកម្មវិធីវិទ្យុនូវសាច់រឿងប្រាំមួយឈុតដែលមានចំណងជើងថា "យើងអាចធ្វើបាន We Can Do It" ដែលជាកម្មវិធីមួយអាចឱ្យសិស្សចែករំលែកនិងទទួលបាននូវ បទពិសោធន៍លើការអប់រំបំណិនជីវិត ។ រាល់ឈុតឆាកដែលបានបង្កើតឡើងមានការចូលរួមសហការពីអ្នកពាក់ពន្ធ័ទាំងអស់តាមរយៈនៃការបង្កើត ក្រុមអ្នកផ្តល់យោបល់លើ មាតិការឿងដោយមានតំណាងពីសាលារៀន សហគមន៍ និងបុគ្គលិករាជរដ្ឋាភិបាល ។ លើសពីនេះទៅទៀត IBEC បានផលិត បោះពុម្ពសៀវភៅកំប្លែងចំនួនពីរ ស្តីពីការអប់រំបំណិនជីវិត ដែលមានចំនួន ២៣០០ ច្បាប់ ហើយបានចែកជូនដល់សាលាចំនួន ៤១ ។

IBECបានជួយដល់សាលាក្នុងការរៀបចំគណៈកម្មាធិការដើម្បីចាត់ចែងជំនួយអាហារូបករណ៍ដល់កុមារដែលងាយរងគ្រោះចំនួន ៣០១៧ នាក់រៀននៅសាលាបឋមសិក្សា និង ៦៣៥ នាក់រៀននៅសាលាមធ្យមសិក្សា ។ អ្វីដែលផ្តោតខ្លាំងគឺសកម្មភាព ជាវិជ្ជមានចំពោះកុមារី ជនជាតិភាគតិច និងជនពិការ ។ លើសពីនេះទៅទៀត IBEC បានផ្តល់អាហារូបករណ៍ដល់សិស្សដែលបានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបឋម ។





IBECបានចំណាយថវិកាប្រមាណជា ១៣២ 000 ដុល្លា ដើម្បីរៀបចំជួសជុល រឺបង្កើតថ្មីនូវប្រព័ន្ធទឹក និងប្រព័ន្ធទឹកស្អាត ដើម្បីឱ្យសាលាចំនួន ១២៨ អាចមានលទ្ធភាពដំណើរការបាននូវការប្រើប្រាស់ទឹក សម្រាប់បង្គន់អនាម័យ ស្រះចិញ្ចឹមត្រីបន្ទប់បាយសាលារៀន និងជួយដល់សេចក្តីត្រូវការផ្សេងៗទៀតដល់សាលាដែលត្រូវការទឹក ។ នៅដំណាច់ឆ្នាំទីមួយនេះមានសាលាចំនួន ៥៦ ហើយដែលបានរៀបចំប្រព័ន្ធរួចរាល់ ។ សិស្សប្រមាណជា ២៦ ៧៤៨ នាក់ កំពុងទទួលបានប្រយោជន៍ ពីប្រព័ន្ធទឹក និងទឹកស្អាត ដែលឧបត្ថម្ភគាំទ្រដោយIBEC នៅតាមបណ្តាខេត្តគោលដៅ ។ IBEC ក៏បានបើកវគ្គបណ្តុះបណ្តាល ជួយដល់នាយកសាលា លោកគ្រូ អ្នកគ្រូក្នុងការរៀបចំអភិវឌ្ឍន៍ផែនការ ដើម្បីធ្វើយ៉ាងណាឱ្យមានការគ្រប់គ្រង និងប្រើប្រាស់ទឹកនេះមាននិរន្តរភាពយូរអង្វែងបន្ទាប់ពីគម្រោងចប់ ។

នាពេលកន្លងទៅកុមារសរុបចំនួន ៤៣៦ នាក់ដែលមិនបានទទួលសេវាអប់រំ ឥឡូវកំពុងតែទទួលបានសេវាអប់រំពីសាលាឆ្លងកាត់ចំនួន១៣ដែលឧបត្ថម្ភសាងសង់ឡើងដោយ IBEC ។ សាលាឆ្លងកាត់ទាំងនោះគ្រាន់តែជាសំណង់ដែលធ្វើឡើងដោយប្រើសម្ភារៈតាមមូលដ្ឋាន និងសាងសង់ដោយសហគមន៍ត្រឹមតែ៦សប្តាហ៍ ជាលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ។ ចំពោះការសាងសង់ដែលមាំទាំមានលក្ខណៈយូរអង្វែងនោះ ជាសំណង់ដែលធ្វើឡើងពីថ្ម ស៊ីម៉ង់ ឥដ្ឋ ហើយជាធម្មតាតាមគម្រោងដែលត្រូវចប់ចាប់តាំងពីផ្តើមគំនិតមកនោះត្រូវប្រើពេលពីរឆ្នាំ ។ សាលាឆ្លងកាត់បានធ្វើឱ្យកុមារដែលពុំបានចូលរៀន រឺកុមារដែលមានការពិបាកធ្វើដំណើរទៅសាលារៀន អាចចូលរៀនបានតាមភូមិរបស់គេដោយមិនធ្វើឱ្យយឺតពេលឡើយ ។ IBEC ក៏បានជួយដល់គ្រួសហគមន៍ ក្នុងការរៀបចំសាលារៀន និងចូលរួមទំនុកបំរុងយកចិត្តទុកដាក់ជាមួយនិងរដ្ឋអំណាចមូលដ្ឋាន ដើម្បីធ្វើយ៉ាងណាឱ្យមានអគារសិក្សាកាន់តែច្រើន និងមានគ្រូដែលមកពីស្ថាប័នរដ្ឋជាប្រចាំ ។





IBEC បានប្រើប្រាស់ថវិកាជាពិសេសចំណាយលើថ្នាក់រៀន ការរៀបចំតំឡើងបន្ទប់ពិសោធន៍ជាង១១ ក្នុងអំឡុងនៃឆ្នាំប្រតិបត្តិដែលក្រៅពីនោះរួមមាន បន្ទប់ពិសោធន៍ព័ត៌មានវិទ្យាចំនួន៨ និងបន្ទប់ពិសោធន៏វិទ្យាសាស្ត្រចំនួន ៣ ។ ថវិកានេះត្រូវចំណាយទៅលើការក្រាលឥដ្ឋការ៉ូ ការបូកលាបជញ្ជាំង ពិដាន និងជួសជុលទ្វារបង្អួចឱ្យមានសុវត្ថិភាព ។ គ្រប់បន្ទប់ពិសោធន៍ទាំងអស់សុទ្ធតែធ្វើយ៉ាងណាឱ្យកាន់តែប្រសើរឡើង ដូចជាប្រព័ន្ធខ្សែភ្លើង និងការរៀបចំទុកដាក់ក្នុងប្រអប់ចំពោះបន្ទប់ ពិសោធន៏វិទ្យាសាស្ត្រ ការរៀបចំតំឡើងឡាវ៉ាបូ(ចានលាងដៃ) ដើម្បីសម្រួលដល់ការពិសោធន៍គីមីវិទ្យា ជីវវិទ្យា និងរូបវិទ្យា ។ ពាក់កណ្តាលនៃការតំឡើងបន្ទប់ពិសោធន៍ព័ត៌មានវិទ្យា គឺប្រើប្រាស់ថវិកាអំណោយសប្បុរសផ្ទាល់ខ្លួន ដែលបានមកពីការរកជំនួយពីអង្គការអប់រំពិភពលោក នេះគឺជាផ្នែកមួយនៃការចូលរួមឧបត្ថម្ភគាំទ្រ ។ សិស្សកម្រិតមធ្យមសិក្សាប្រមាណជា ៦ ៦៤០នាក់កំពុងទទួលបានប្រយោជន៍ពីលទ្ធផលទាំងនោះ ក្រោមការដឹកនាំរបស់ IBEC ។

IBEC បានរៀបចំរួចរាល់ជាស្រេចហើយនូវវគ្គបណ្តុះបណ្តាលការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ ដែលជាគោលគំនិតផ្តួចផ្តើមយ៉ាងសំខាន់ផ្តោតទៅលើការកសាងសមត្ថភាព ផ្នែកនេះពិតជានឹងមានសារៈប្រយោជន៍ ដែលនឹងធ្វើឱ្យរាល់សកម្មភាព អនុវត្តរបស់ IBEC នឹងទទួលបានជោគជ័យលើរាល់កិច្ចអន្តរាគមន៍គ្រប់ សមាសភាគទាំងអស់ ។ គម្រោងនៃកម្មវិធីវគ្គបណ្តុះបណ្តាលនេះមានរយៈពេលទាំងអស់ពីរឆ្នាំ ដែលត្រូវបាន រៀបចំជាស្រេចអស់ហើយនាដំណាច់ខែកក្កដា ២០១០ កន្លងមក ។ ការបើកវគ្គបណ្តុះបណ្តាលលើផ្នែក ការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ ក៏បានចាប់ផ្តើមហើយដែរនាដំណាច់ឆ្នាំទីមួយ ហើយវគ្គបណ្តុះ បណ្តាលនេះនឹងត្រូវអនុវត្តបន្តជាប់រហូតក្នុងរយៈពេលពីរឆ្នាំ គឺឆ្នាំទី២ និងទី៣នៃការប្រតិបត្តិគម្រោង ។





ចំនួនសាលាសរុប ១៨៣ បានសម្រេចលើផែនការកែលម្អសាលារៀន ហើយបានស្របតាមបទដ្ឋាន ដែលបានដាក់ចេញពីសិក្ខាសាលាស្តីពីការបែងចែកអំណោយ ។ ការអភិវឌ្ឍន៍ផែនការកែលម្អសាលារៀន គឺជាសកម្មភាពចំបងមួយនៅក្នុងគម្រោង IBEC ដែលជំរុញឱ្យអ្នកពាក់ព័ន្ធគ្រប់គ្រងលើដំណើរការរៀបចំគម្រោង ហើយចំបាច់ត្រូវផ្អែកលើការវាយតម្លៃតាមបរិបទមូលដ្ឋាន ។ ទាំងនេះរួមមានការប្រើបញ្ជីសកម្មភាព (activity menus) ឯកសារបណ្តុះបណ្តាលបំប៉ន ក្រុមពិនិត្យការងារខេត្ត និងដំណើរការអនុម័ត ដែលធានាធ្វើយ៉ាងណាឱ្យមានការចូលរួមពីរដ្ឋអំណាចមូលដ្ឋាន ។

IBEC ក៏បានរៀបចំជាស្រេចហើយដែរនូវផែនការសកម្មភាពបំណិនជីវិត ការបង្កើតគោលការណ៍ប្រតិបត្តិ និងឯកសារបំប៉នគ្រូបង្រៀន ដើម្បីអនុវត្តសកម្មភាពបំណិនជីវិតសាកល្បងនៅតាមសាលាមធ្យមសិក្សាបឋមភូមិចំនួនជាង ៤០ ទៀត នៅឆ្នាំ ២០១០-២០១១ នេះ ។ លើសពីនេះទៅទៀត IBEC ក៏បានបង្កើតសៀវភៅប្រធានបទបំណិនជីវិតចំនួន ១១ ទៀតផងដែរ ដើម្បីជាមគ្គុទ្ទេសន៍ដល់លោកគ្រូអ្នកគ្រូក្នុងការបង្រៀនរបស់ពួកគេ ។



Visit IBEC on the Web for key project updates, information and resources!
**WWW.ibec.worlded.org**

## សមាសភាគ ១ : ការកសាងសមត្ថភាពរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ព្រមទាំងការស្វែងរកការគាំទ្រសម្រាប់និរន្តរភាព

ដំណើរការនៃការរៀបចំក្រុមការងារថ្នាក់ខេត្តបានចាប់ផ្តើមនៅក្នុងអំឡុងត្រីមាសទីពីរនៃឆ្នាំទីមួយ ទោះបីជាមានកម្មវិធីរវល់ជាច្រើននៅការិយាល័យអប់រំខេត្តយ៉ាងណាក៏ដោយ ក៏ខេត្តក្រចេះត្រូវបានរៀបចំធ្វើហើយរួចរាល់នូវដំណើរការក្រុមការងារថ្នាក់ខេត្តនៅពេលជាមួយគ្នានេះដែរ ។ ចំពោះការងារថ្នាក់ខេត្តសៀមរាប និងកំពង់ចាមត្រូវបានរៀបចំស្រេចបាច់រហូតដល់ត្រីមាសទីបី ។ គ្រប់ក្រុមការងារថ្នាក់ខេត្តទាំងអស់បានចេញលិខិតតែងតាំងដល់សមាជិករបស់គេដើម្បីចូលរួមប្រជុំស្តីពីគោលការណ៍ប្រតិបត្តិការណ៍តម្រង់ទិសអំឡុងខែឧសភា និងខែមិថុនា ឆ្នាំ ២០១០ ។

ការចាប់ផ្តើមលើផ្នែកពង្រឹងសមត្ថភាពសម្រាប់គណៈកម្មាធិការការសិក្សាដើម្បីទាំងអស់គ្នាថ្នាក់ឃុំបានផ្តោតលើសកម្មភាពបណ្តុះបណ្តាលបន្ថែមសម្រាប់សមាជិកចំនួន ១២ នាក់ ដែលបានចូលរួមការងារក្រោមគម្រោងសាលារៀន ដើម្បីជីវិតកាលពីពេលកន្លងទៅរបស់ USAID ឃុំទាំងអស់នេះមាននៅខេត្តកំពង់ចាម និងក្រចេះ ។ ការខំប្រឹងប្រែងលើផ្នែកពង្រឹងសមត្ថភាពក្នុងឆ្នាំទីមួយនេះ ប្រធានបទដែលបានយកមកបណ្តុះបណ្តាលរួមមាន : ទស្សនៈវិស័យរបស់ IBEC ការពិនិត្យឡើងវិញនូវគោលនយោបាយលើការសិក្សាដើម្បីទាំងអស់គ្នា យុទ្ធសាស្ត្រផែនការអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា គោលនយោបាយសាលាកុមារមេត្រី និងការចូលរួមពីគណៈកម្មាធិការ ការសិក្សាដើម្បីទាំងអស់គ្នាថ្នាក់ឃុំនៅក្នុងគម្រោង IBEC ។

សមាភាគទី១មានអាណត្តិច្បាស់លាស់ក្នុងការជំរុញឱ្យគម្រោងមាននិរន្តរភាពនូវអ្វីដែលធ្វើបានតាមរយៈនៃការពង្រឹងស្ថាប័ននៃការកសាងសមត្ថភាព ក៏ដូចជាការផ្សព្វផ្សាយនូវការអនុវត្តន៍ជាគំរូល្អៗដូចជាតាមរយៈកម្មវិធីវិទ្យុ ការផលិត និងបោះពុម្ពឯកសារស្រាវជ្រាវរបស់គម្រោងដែលទាក់ទងទៅនឹងវិស័យទាំងនោះ ។ នៅឆ្នាំទីមួយនេះ IBEC បានផលិត និងចាក់ផ្សាយតាមកម្មវិធីវិទ្យុនូវសាច់រឿង៦ឈុត ដែលមានឈ្មោះ ថា ( យើងអាចធ្វើបាន called We Can Do It ) ដែលអាចឱ្យសិស្សទទួល និងចែករំលែករាល់បទពិសោធន៍របស់គេអំពីការអប់រំបំណិនជីវិត ។ ប្រធានបទស្តីពីការអប់រំបំណិនជីវិតត្រូវបានស្តាប់យ៉ាងយកចិត្តទុកដាក់នៅតាមសាលាជាច្រើន ដោយមានការរៀបចំជាប្រព័ន្ធនៅក្នុងក្រុមអ្នកស្តាប់និងឆ្លើយឆ្លងដែលបានបង្កើតឡើងនៅតាមសាលាគោលដៅចំនួន ១៣ ។ ចំពោះការខិតខំយកចិត្តទុកដាក់លើផ្នែកនេះ រួមមានការបង្កើត audio ពីរដើម្បីហ្វឹកហាត់លើការស្តាប់ និងប្រើសម្លេង និងបានបង្កើតចងក្រងបានជាសៀវភៅតាមបែបកំប្លែងពីរ ដែលផ្តោតលើប្រធានបទបំណិនជីវិត ។ ការបង្កើតបន្ថែមពីលើព្រឹត្តិបត្រព័ត៌មានដើម្បីបង្ហាញនូវដំណើរការដែលគម្រោងបានអនុវត្ត និងទទួលជោគជ័យ ។ IBEC ក៏បានបង្កើតគេហទំព័រផងដែរ ។ ការចូលមើលគេហទំព័រនោះ គ្រាន់តែវាយអក្សរ ( www.ibec.worled.org ) ។

សកម្មភាពស្រាវជ្រាវរបស់ IBEC នៅឆ្នាំទីមួយ រួមមានការស្រាវជ្រាវលើការបែងចែកអាហារូបករណ៍នៅសាលាបឋមសិក្សា ធ្វើយ៉ាងណាឱ្យមានប្រសិទ្ធិភាព ( ការគាំទ្រ និងដំណោះស្រាយនៅពេលអនាគត) និងឥរិយាបថផ្តត់គំនិតក្នុងចំណោមនាយកសាលាលើការអភិវឌ្ឍន៍ ។



## សមាសភាគ ២ : សមធម៌ក្នុងការទទួលបានការអប់រំច្រើនជាងមុន

សមាសភាគនេះបានផ្តោតទៅលើការពង្រីកសកម្មភាពលើកកម្ពស់ធ្វើយ៉ាងណាឱ្យការចុះឈ្មោះចូលរៀនរបស់កុមារមាននិរន្តរភាព និងការឆ្លងពីបឋមសិក្សាទៅមធ្យមសិក្សា ។ កសម្មភាពទាំងនោះរួមមានការផ្តល់អាហារូបណ៍ដល់គ្រប់កម្រិតសិក្សា ក្រុមប្រឹក្សាកុមារ ការប្រមែប្រមូលកុមារឱ្យចូលរៀន ការចុះជួយដល់ក្រុមកុមារងាយរងគ្រោះ ដូចជាកុមារជនជាតិភាគតិច កុមារពិការ តាមរយៈប្រព័ន្ធកុមារជួយកុមារ និងតាមរយៈក្រុមការងារផ្សេងៗទៀត ។

នៅឆ្នាំទីមួយនេះ IBEC ទទួលបានជោគជ័យយ៉ាងធំធេងលើការផ្តល់អាហារូបករណ៍ ដែលបានជួយដល់សិស្សបឋមសិក្សាចំនួន ៣ ០១៧ នាក់ មធ្យមសិក្សាចំនួន ៦៣៩នាក់ និងសិស្សរៀននៅសាលាគរុកោសល្យចំនួន ១២០នាក់ ។ IBEC ផ្តោតសំខាន់ទៅលើសេចក្តីត្រូវការលើការអប់រំរបស់ពលរដ្ឋភាគច្រើន ដែលពុំបានទទួលសេវានេះ ។ ក្នុងចំណោមសិស្សបឋមសិក្សា និងមធ្យមសិក្សាដែលទទួលបានអាហារូបករណ៍សម្រាប់ឆ្នាំនេះជាសរុបពី ៩៥% ( បឋមសិក្សា ៩៧% និងមធ្យមសិក្សា ៨៨% ) ។

អត្រាបោះបង់ការសិក្សាត្រូវបានថយចុះ ប៉ុន្តែអ្វីដែលខុសគ្នានោះគឺវាអាស្រ័យទៅតាមតំបន់ និងភេទដែលតម្រូវការជំនួយបន្ថែមនោះគឺកុមារី ដូចនេះហើយបានជាកម្មវិធីអាហារូបករណ៍មានការកើនឡើងគួរឱ្យកត់សម្គាល់ ពិសេសផ្តោតលើកុមារីដែលកម្មវិធីនឹងត្រូវអនុវត្តបន្តនៅឆ្នាំទី២ ។

ចំពោះកម្រិតបឋមសិក្សា IBEC បានផ្តោតទៅលើសាលាកម្រង ៣០ នៅឆ្នាំទី១ ដែលសាលាចំណុះទាំងនោះមានគោលដៅទៅលើសាលាមធ្យមសិក្សាបឋមភូមិ ។ សាលាកម្រងទាំងអស់ត្រូវបានទទួលមូលនិធិសរុបចំនួន ៦៦ ៥២៦ ដុល្លា ដើម្បីរៀបចំផែនការថវិកាទៅលើគម្រោងឯកសារផ្សេងៗដែលមានចំនួនជាមធ្យមប្រហែលជា ២ ២០០ដុល្លា ក្នុងមួយកម្រង ។ តាមការពិនិត្យលើផែនការប្រចាំឆ្នាំបង្ហាញឱ្យឃើញថាមានសកម្មភាព ៤៤ ដោយឡែកៗពីគ្នាដែលត្រូវបានកំណត់នៅក្នុងផែនការកម្រង ។ ទំហំនៃការពង្រីកសាលាកុមារមេត្រីចំនួន៦ ដែលត្រូវបានពន្យល់យ៉ាងច្បាស់ក្រោមគោលនយោបាយរបស់ក្រសួងអប់រំ ។ ចំនុចខ្លាំងនៃតួនាទីសកម្មភាពដែលបានកំណត់របស់អ្នកដែលពាក់ព័ន្ធ គឺសុទ្ធតែផ្អែកលើសេចក្តីត្រូវការតាមមូលដ្ឋាន ។

ផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់មធ្យមសិក្សាបឋមភូមិត្រូវបានធ្វើហើយដែលមានចំនួនជាសរុប៧៦ ដោយប្រើយុទ្ធសាស្ត្រលើការចូលរួមពីសហគមន៍ និងអ្នកដែលពាក់ព័ន្ធ ដូចដែលបានបង្ហាញសម្រាប់សាលាបឋមសិក្សា ។ ចំនួនសាលាដែលត្រូវបានកំនត់ជាសរុបមានចំនួន ៤៧ ដែលមានសកម្មភាពប្រតិបត្តិដោយឡែកៗពីគ្នា ដើម្បីធ្វើឱ្យបរិយាកាសរៀនសូត្រកាន់តែមានមេត្រីភាព និងមានភាពស្និទ្ធស្នាលតាមបែបសាលាកុមារមេត្រី ។ សាលាពេញជុំបានធ្វើផែនការសម្រាប់ការងារមួយឆ្នាំពេញនៅក្នុងខែវិច្ឆិកា ២០០៩ ហើយទទួលបានមូលនិធិឧបត្ថម្ភមួយឆ្នាំពេញ ។ សាលាពាក់កណ្តាលជុំបានរៀបចំធ្វើផែនការនៅដំណាច់ចុងត្រីមាសទីមួយ ដោយទទួលបានមូលនិធិឧបត្ថម្ភតែសម្រាប់កន្លះឆ្នាំប៉ុណ្ណោះ ដែលផ្តោតតែលើសកម្មភាពការងារចាប់ផ្តើមដំបូងក្នុងការរៀបចំសម្រាប់ឆ្នាំទីពីរ ។ ការងារទាំងនោះរួមមាន ការរៀបចំក្រុមប្រឹក្សាសិស្ស ទីប្រឹក្សាកុមារី និងសកម្មភាពមូលដ្ឋានបំណិនជីវិត ។

ចំពោះសាលាមធ្យមសិក្សា ដែលជាទិសដៅប្រតិបត្តិត្រូវបានផ្តល់មូលនិធិជាសរុបចំនួន ៧៥ ៧៣៩ ដុល្លា ដើម្បីរៀបចំថវិការបស់គេលើផ្នែកឯកសារគម្រោង ។ ថវិកានេះត្រូវបានបែងចែកចំនួនប្រហែល ១ ៨០០ដុល្លា ជាមធ្យមសម្រាប់សាលានីមួយៗ ( ចំនួនទឹកប្រាក់នេះសម្រាប់សាលាពេញជុំ និងប្រហែលជាពាក់កណ្តាលនេះសម្រាប់សាលាពាក់កណ្តាលជុំ) ។

ការត្រួតពិនិត្យលើផែនការប្រតិបត្តិរបស់សាលាមធ្យមសិក្សាបានឱ្យឃើញថាសកម្មភាពជាច្រើនដែលត្រូវបានជ្រើសឡើងនោះរួមមានសម្ភារៈជំនួយបឋម ក្រុមប្រឹក្សាសិស្ស និងការវាយតម្លៃសាលាដោយខ្លួនឯង ។ ជាថ្មីម្តងទៀតសូមបញ្ជាក់ផងដែរថាទំហំនៃសកម្មភាព ដែលត្រូវបានជ្រើសរើសនោះ ( ជាសរុប មានចំនួន ៤៧) នេះជាការបង្ហាញឱ្យឃើញនូវការប្រែប្រួលដែលលេចធ្លោគួរឱ្យកត់សំគាល់ចំពោះការទទួលយល់ដឹងពីសេចក្តីត្រូវការរបស់សាលានីមួយៗ ។ ការសម្របសម្រួលបត់បែនរបស់គម្រោង IBEC នូវរាល់សេចក្តីត្រូវការទាំងនេះ គឺពិតជាបានពង្រឹងនូវប្រសិទ្ធិភាព និងភាពជាម្ចាស់ ។

## សមាសភាគ ៣ ៖ កែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍

សកម្មភាពរបស់ IBEC ពាក់ព័ន្ធនឹងការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍បានយឺតយ៉ាវក្នុងការចាប់ផ្តើមនៅក្នុងឆ្នាំទីមួយដោយសារផ្តែកសំខាន់នៃគម្រោងបានចាប់ផ្តើមយឺតមិនស្របនឹងឆ្នាំសិក្សា ២០០៩-២០១០ ។ទោះបីជាយ៉ាងណាក៏ដោយ បុគ្គលិកសមាសភាគនេះបានបញ្ចប់ការបង្កើតវគ្គបណ្តុះបណ្តាលការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ ។ ទាំងនេះគឺជាគំនិតផ្តួចផ្តើមកសាងសមត្ថភាពគន្លឹះមួយដែលនឹងមានភាពចាំបាច់ចំពោះការសម្រេចជោគជ័យក្នុងការអនុវត្តន៍អន្តរាគមន៍របស់ IBEC នៅទូទាំងសមាសភាគទាំងអស់ ។ ដោយមានជំនួយពីសំណាក់អ្នកឯកទេសក្នុងការគ្រប់គ្រងសាលារៀន ព្រមទាំងការពិគ្រោះយោបល់ដ៏ទូលំទូលាយជាមួយនឹងកម្មវិធីគ្រប់គ្រងសាលារៀនដទៃផ្សេងទៀត ការគូសបញ្ជាក់រួមអំពីកម្មវិធីបណ្តុះបណ្តាលរយៈពេលពីរឆ្នាំត្រូវបានបញ្ចប់ត្រឹមដំណាច់ខែ កក្កដា ឆ្នាំ២០១០ ។ IBEC មានការស្ញើចសរសើរយ៉ាងខ្លាំងចំពោះកិច្ចសហការណ៍ដ៏ល្អជាមួយកម្មវិធីគាំទ្រវិស័យអប់រំកម្ពុជារបស់ MoEYS (CESSP) ដែលបាន អនុញ្ញាតអោយ IBEC បង្កើតនូវកម្មវិធីបណ្តុះបណ្តាលរបស់ពួកគេ និងប្រើប្រាស់កម្មវិធីនេះជាមូលដ្ឋានសម្រាប់អន្តរាគមន៍ក្នុងការរៀបចំ និងភាពជាអ្នកដឹកនាំសម្រាប់ IBEC ។ វគ្គបណ្តុះបណ្តាលការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំត្រូវបានដាក់ឱ្យអនុវត្តនៅតាមសាលារៀននានា នៅដំណាច់ឆ្នាំទីមួយហើយនឹងត្រូវអនុវត្តសម្រាប់រយៈពេលពីរឆ្នាំជាប់ៗគ្នា ( ការអនុវត្តគម្រោងសម្រាប់ឆ្នាំទីពីរ និងទីបី) ។

បន្ថែមលើការរៀបចំនិងសកម្មភាពនានាពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពរបស់នាយកសាលា IBEC ក៏បានផ្តោតផងដែរលើការពង្រឹងគណៈកម្មាធិការទ្រទ្រង់សាលារៀន (SSCs) ។ IBEC បានផ្តល់សិក្ខា សាលាបណ្តុះបណ្តាលមួយដល់ SSCs ចំនួន ១៩៦ និង CEFACs ចំនួន ១២ នៅក្នុងខេត្តកំពង់ចាម ។ សិក្ខាសាលាបណ្តុះបណ្តាលបានធ្វើឡើងនៅកម្រិតថ្នាក់ស្រុក ដោយមានសិក្ខាកាមចូលរួមចំនួន ៣៨៨ នាក់ដែលក្នុងនោះមានដូចជាអ្នកគ្រប់គ្រងសាលារៀន និងតំណាងសហគមន៍ ដែលស្ថិតនៅក្នុងគណៈកម្មាធិការផ្សេងៗ ។ ប្រធានបទសំខាន់ៗសម្រាប់កិច្ចពិភាក្សាក្នុងអំឡុងពេលធ្វើសិក្ខាសាលារួមមានការណែនាំអំពី IBEC គោលនយោបាយ CFS ព្រមទាំងតួនាទី និងការទទួលខុសត្រូវរបស់ SSCs នៅក្នុងដំណើរការសាលារៀន ដូចជាការកំណត់អត្តសញ្ញាណសិស្សងាយរងគ្រោះ ដើម្បីទទួលការគាំទ្រពិសេស និងការចូលរួមរៀបចំផែនការកែលម្អសាលារៀន ។

នៅក្នុងឆ្នាំទីមួយ មានសាលារៀនចំនួន ២០៩ បានបញ្ចប់ផែនការកែលម្អសាលារៀន ។ ការធ្វើផែនការកែលម្អសាលារៀន គឺជាសកម្មភាពគន្លឹះមួយនៅក្នុង IBEC និងផ្សព្វផ្សាយអំពីការគ្រប់គ្រងដំណើរការរៀបចំផែនការរបស់បុគ្គលពាក់ព័ន្ធ ក៏ដូចជាការវាយតម្លៃផ្អែកលើតម្រូវការនៃបរិបទក្នុងតំបន់ផងដែរ ។ វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់សម្រាប់ទាំងសាលាបឋមសិក្សា និងសាលាមធ្យមសិក្សា ហើយព្រមទាំងរួមបញ្ចូល នូវការប្រើប្រាស់បញ្ជីសកម្មភាព ឯកសារបណ្តុះបណ្តាល និងការពិនិត្យឡើងវិញនិងឯកភាពរបស់ក្រុមការងារខេត្តដើម្បីធានាបានដល់ការចូលរួមពីសំណាក់រដ្ឋអំណាចមូលដ្ឋាន ។

## សមាសភាគ ៤ ៖ បង្កើនបរិបទពាក់ព័ន្ធលើការអប់រំ

កិច្ចការរបស់សមាសភាគនេះត្រូវបានបង្កើត និងអនុវត្តកម្មវិធីបំណិនជីវិតថ្មី ដែលស៊ីសង្វាក់គ្នានឹងគោលការណ៍របស់ MoEYS និងមានបរិបទពាក់ព័ន្ធលើការអប់រំចំពោះក្រុមមនុស្សគោលដៅ ។ ក្នុងឆ្នាំទីមួយនៃគម្រោង IBEC សម្រេចបាននូវព្រឹត្តការណ៍មួយចំនួនទាក់ទិននឹងការរៀបចំកម្មវិធីបំណិនជីវិតដ៏ទូលំទូលាយមួយសម្រាប់សាលាមធ្យមសិក្សាបឋមភូមិ ។ គម្រោងបានទទួលជោគជ័យក្នុងការបញ្ចប់ការបង្កើតក្របខ័ណ្ឌបំណិនជីវិតទស្សនាទាន និងការបង្កើតគោលការណ៍ណែនាំអនុវត្តនិងសៀវភៅណែនាំបណ្តុះបណ្តាលគ្រូសម្រាប់ការរៀបចំអនុវត្តសាកល្បងនៅតាមសាលាមធ្យមសិក្សាបឋមភូមិក្នុងឆ្នាំសិក្សា ២០១០-២០១១ ។

ក្រៅពីការរៀបចំនៅកម្រិតមជ្ឈិមសម្រាប់វិធីសាស្ត្រសមាហរណកម្មមួយលើការរៀបចំកម្មវិធីបំណិនជីវិត ។ សកម្មភាពបំណិនជីវិតដំបូងមួយចំនួនត្រូវបានអនុវត្តនៅកម្រិតសាលារៀនដើម្បីអោយសាលារៀនគោលដៅបច្ចុប្បន្នអាចកសាងនូវបទពិសោធន៍មូលដ្ឋានមួយចំនួនក្នុងការអនុវត្តបំណិនជីវិត ។ សិស្សនៅតាមសាលារៀនរបស់ IBEC មានឱកាសសិក្សាអំពីបំណិនជីវិតផ្សេងៗក្នុងរយៈពេលពេញមួយឆ្នាំ ដែលនេះបានបង្ហាញក្នុងសកម្មភាពផ្សារប្រឌិត ។ ព្រឹត្តិការណ៍ដែលមានភាពរីករាយដល់សិស្សទាំងនេះ ត្រូវបានរៀបចំធ្វើឡើងនៅតាមសាលារៀនមួយចំនួន នៅថ្ងៃទី ០១ ខែមិថុនា ដែលជាថ្ងៃប្រារព្ធទិវាកុមារអន្តរជាតិ ។

សមាសភាគនេះក៏បានផ្តល់ដល់គ្រូផងដែរនូវការជួយជ្រោមជ្រែងផ្តល់ការណែនាំក្នុងថ្នាក់រៀនធម្មតារបស់ពួកគេ ដើម្បីលើកកំពស់ការរៀនសូត្រតាមបែបសិស្សមជ្ឈមណ្ឌល និងក្នុងករណីខ្លះបានផ្តល់នូវការគាំទ្របច្ចេកទេសប្រមូលផ្តុំនៅក្នុងមុខវិជ្ជាដែលបានជ្រើសរើសដូចជា គីមីវិទ្យា រូបវិទ្យា និង ICT ។

កិច្ចការសំខាន់ទីពីរសម្រាប់សមាសភាគនេះ គឺផ្តល់ការអប់រំដល់គ្រូក្នុងការអនុវត្តកម្មវិធីបំណិនជីវិតបន្ថែមលើការគាំទ្រផ្អែកគរុកោសល្យទូទៅ និងការលើកកំពស់បរិយាកាសរៀនសូត្រកុមារមេត្រី ។ ក្នុងអំឡុងឆ្នាំទីមួយ IBEC បានធ្វើសកម្មភាពជាច្រើនដើម្បីជួយជ្រោមជ្រែងដល់គ្រូនៅក្នុងកម្រិតផ្សេងៗ ជាមួយនឹងការអនុវត្តន៍អន្តរាគមន៍បង្កើនគុណភាព ។ តាំងពីពេលចាប់ផ្តើមគម្រោង គ្រូមួយចំនួនធំបានទទួលការបណ្តុះបណ្តាលស្តីពីទស្សនាទានសាលាកុមារមេត្រី នៅកម្រិតសាលាបឋមសិក្សា និងមធ្យមសិក្សា ។ គ្រូបឋមសិក្សាសរុបចំនួន ៤២១ នាក់ ទទួលការបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន និងរៀនសូត្រសាលាកុមារមេត្រី ដើម្បីលើកកំពស់នៅតាមសាលាបឋមសិក្សា និងការបន្តចូលទៅ សាលាមធ្យមសិក្សាបឋមភូមិ ។ ជាងនេះទៅទៀត គ្រូមធ្យមសិក្សាចំនួន ៣៥៤ នាក់ត្រូវបានបណ្តុះបណ្តាលនៅក្នុងឆ្នាំនោះក្នុងសិក្ខាសាលាស្តីពីការរៀបចំកម្មវិធីសាលាកុមារមេត្រី និងបំណិនជីវិត ។

ដើម្បីតាមដានសិក្ខាសាលាបណ្តុះបណ្តាលដំបូងៗទាំងនេះ វគ្គឆ្លុះបញ្ចាំងនានាត្រូវបានរៀបចំធ្វើឡើងដើម្បីផ្តល់ដល់គ្រូនូវឱកាស ក្នុងការចែករំលែកបទពិសោធន៍ក្នុងការអនុវត្តន៍វិធីសាស្ត្រថ្មីៗទាំងនេះ ។ក្រុមការងារបច្ចេកទេសក៏បានរៀបចំវាយតម្លៃការបង្រៀនរបស់គ្រូ ដែលត្រូវបានធ្វើ ឡើងនៅក្នុងខែកក្កដា ឆ្នាំ ២០១០ នៅចុងឆ្នាំសិក្សាដើម្បីវាស់ស្ទង់នូវវឌ្ឍនភាពនិងតម្រូវការការបណ្តុះបណ្តាលសម្រាប់ឆ្នាំបន្ទាប់ ។

សម្រាប់គ្រូនៅសាលាមធ្យមសិក្សាបឋមភូមិ IBEC បានរៀបចំវគ្គតម្រង់ទិសគ្រូលើថ្នាក់រៀនសម្រាប់មុខវិជ្ជាជាក់លាក់ និងការផ្តល់នូវសម្ភារៈសិក្សាពាក់ព័ន្ធ ។ ការបង្កើតថ្នាក់រៀនសម្រាប់មុខវិជ្ជាជាក់លាក់ គឺជាកត្តាសំខាន់មួយក្នុងចំណោមកត្តា



សំខាន់ៗផ្សេងទៀតរបស់សាលាមធ្យមសិក្សាកុមារមេត្រី ដោយសារថ្នាក់រៀនទាំងនោះបង្កលក្ខណៈងាយស្រួលដល់សិស្សក្នុងការទទួលបានសម្ភារៈសិក្សានៅពេលរៀនមេរៀន ។ ជំហានដ៏សំខាន់មួយទៀតចំពោះការបង្កើនគុណភាពថ្នាក់រៀននៅសាលាមធ្យមសិក្សា គឺការបង្កើតបន្ទប់ពិសោធន៍បច្ចេកវិទ្យាព័ត៌មានចំនួនប្រាំបី និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រចំនួនបីក៏ដូចជាការតម្រង់ទិសគ្រូអំពីវិធីប្រើប្រាស់បរិក្ខារទាំងនោះឱ្យបានប្រសើរបំផុត ។ IBEC ទទួលស្គាល់នូវតម្រូវការបណ្តាញទ្រទ្រង់ដ៏រឹងមាំមួយសម្រាប់គ្រូ ដើម្បីណែនាំពួកគេក្នុងការអនុវត្តន៍កិច្ចអន្តរាគមន៍ផ្សេងៗ ដោយសារតែគម្រោងបានណែនាំនូវវិធីសាស្ត្រ និងសកម្មភាពថ្មីៗជាច្រើន ។ ជាការឆ្លើយតបចំពោះតម្រូវការនេះ ក្រុមគាំទ្របច្ចេកទេស (TSGs) ត្រូវបានបង្កើតឡើងនៅតាមសាលាបឋមសិក្សា និងសាលាមធ្យមសិក្សាបឋមភូមិនានាដើម្បីទុក ជាយន្តការសម្រាប់បន្តផ្តល់ការគាំទ្របច្ចេកទេសដល់គ្រូ ។